# កម្ពុជា
## របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៣៧
១៥ មីនា ឆ្នាំ២០២១
របាយការណ៍គិតត្រឹមថ្ងៃទី ១៥ មីនា ឆ្នាំ២០២១ ម៉ោង១០:០០នាទីព្រឹក

## ស្ថានការណ៍សង្ខេប
### សម្រង់សង្ខេបនៃរបាយការណ៍អំពីស្ថានភាពជំងឺកូវីដ-១៩ ពេលបច្ចុប្បន្ន

- ក្នុងរយៈពេល៧ថ្ងៃចុងក្រោយ មានករណីឆ្លងជំងឺកូវីដ-១៩ឆ្លងនៅក្នុងប្រទេសចំនួន ៣០៩ករណី។ ចំនួននេះធ្វើឲ្យករណីវិជ្ជមានសរុបពាក់ព័ន្ធនឹងព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ ២០២១ឡើងដល់ ៨១០ករណី (ស្រី៣៧៨ និងប្រុស៤៣២ករណី)។
- កាលពីថ្ងៃទី ១១ ខែមីនា ឆ្នាំ២០២១ ករណីស្លាប់ដំបូងដោយសារជំងឺកូវីដ-១៩ ត្រូវបានរាយការណ៍។ នោះជាករណីបុរសអាយុ៥០ឆ្នាំម្នាក់។ ហើយត្រឹមថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២១ មានករណីជាសះស្បើយចំនួន ២៣១ករណី ហើយ ៥៧៩ករណីទៀតកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬក៏ត្រូវបានដាក់ឲ្យដាច់ដោយឡែករង់ចាំទទួលការព្យាបាល។
- ករណីវិជ្ជមានវីរុសកូវីដ-១៩ពាក់ព័ន្ធនឹងព្រឹត្តិការសហគមន៍២០កុម្ភៈ ត្រូវបានរាយការណ៍នៅក្នុងរាជធានី-ខេត្តចំនួន១០។ ខេត្តបន្ថែមថ្មីរួមមាន ខេត្តបាត់ដំបងដែលមាន០១ករណី និង ខេត្តសៀមរាបដែលមានមួយករណីត្រូវបានរាយការណ៍នៅក្នុងសប្តាហ៍នេះ។
- កន្លងមកចង្កោមដែលមានករណីវិជ្ជមានចំនួន២០ និងទីតាំងចំនួន ២០០កន្លែងត្រូវបានកំណត់ថាពាក់ព័ន្ធ តាមរយៈការស៊ើបអង្កេតរកករណីវិជ្ជមាន និងការតាមរកអ្នកពាក់ព័ន្ធ។
- រដ្ឋាភិបាលបានអនុវត្តនូវអន្តរាគមន៍មិនមែនវេជ្ជសាស្ត្រសម្រាប់គោលដៅជាក់លាក់នៅក្នុងបណ្តាខេត្តមួយចំនួនដោយមានរួមទាំងការបង្កើនចំនួនសាលារៀនដែលត្រូវបិទជាបណ្តោះអាសន្ន ការរឹតបន្តឹងការធ្វើដំណើរ និងការបិទទីតាំងកំសាន្តដែលជាកន្លែងជាប់ពាក់ព័ន្ធនឹងព្រឹត្តិការសហគមន៍២០កុម្ភៈ។
- ក្រសួងអប់រំ យុវជននិងកីឡា បានប្រកាសបិទគ្រឹះស្ថានអប់រំរដ្ឋ និងឯកជនទាំងអស់នៅក្នុងខេត្តព្រៃវែង។
- អាជ្ញាធរខេត្តកំពង់ចាម ខេត្តស្វាយរៀង ខេត្តប៉ៃលិន ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យបានប្រកាសផ្អាករាល់ពិធីរៀបអាពាហ៍ពិពាហ៍ កម្មវិធីជួបជុំ និងពិធីសាសនានានា។
- ក្រសួងសុខាភិបាល កំពុងធ្វើការវាយតម្លៃហានិភ័យ ការតាមដានរកជំងឺរលាកសួតយ៉ាងសកម្ម ការធ្វើតេស្តនៅតំបន់ពាក់ព័ន្ធ ការប្រើវិធីសាស្ត្រប្រើចង្កោមដែលបានឆ្លងដើម្បីកំណត់រកករណី និងស្វែងរកអ្នកពាក់ព័ន្ធ និងគ្រប់គ្រងករណី។
- អង្គការសុខភាពពិភពលោក និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃសហរដ្ឋអាមេរិក កំពុងជួយគាំទ្រនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល ដើម្បីអនុវត្តវិធីសាស្ត្ររាំងខ្ទប់ការចម្លងតាមចង្កោម ដោយរួមមានទាំងការកំណត់ត្រូវមានចំណាត់ការនៅទីតាំងឆ្លងជាចង្កោម និងកន្លែងបិទជិត និងមនុស្សអ៊ូអរណាសម្រាប់ការស៊ើបអង្កេត និងការធ្វើតេស្តមុនគេ។
- កាលពីថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២១ ករណីវិជ្ជមានវីរុសកូវីដ-១៩ មួយករណីត្រូវបានរកឃើញលើពលករចំណាកស្រុកវិលមកពីប្រទេសថៃ។
- គិតត្រឹមថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង១០សកល មានអ្នកវិជ្ជមានវីរុសកូវីដ-១៩ ចំនួនសរុប ១.៣២៥ករណី (ក្នុងនោះមានស្រី ៥៦០នាក់ និងប្រុស ៧៦៥នាក់) ដែលត្រូវបានបញ្ជាក់ថាជាករណីជំងឺកូវីដ-១៩ និងករណីស្លាប់មួយករណី ត្រូវបានរាយការណ៍ដោយរដ្ឋាភិបាលកម្ពុជា។ ក្នុងចំណោមនោះមានចំនួន ៧៣០ករណីបានជាសះស្បើយ។ ចំនួន ៩២៤ ករណី ដែលបានឆ្លងពីបរទេស ២២សញ្ជាតិផ្សេងៗគ្នា បន្ថែមទៅលើជនជាតិខ្មែរ ហើយករណីដែលនៅសេសសល់ជាករណីដែលទទួលបានការឆ្លងនៅក្នុងស្រុក។ អ្នកជំងឺកូវីដ-១៩ ចំនួន ៥៩២នាក់ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ។
- ឥឡូវនេះ វ៉ាក់សាំងកូវីដ-១៩ ស៊ីណូហ្វាម ត្រូវបានចាក់ជូននៅតាមមន្ទីរពេទ្យរដ្ឋទាំងអស់នៅទូទាំងខេត្ត និងស្រុកប្រតិបត្តិនៅកម្ពុជា។
- គិតត្រឹមថ្ងៃទី ១៤ មីនា ឆ្នាំ២០២១ ពលរដ្ឋចំនួន ១៧០.៦៥៩នាក់ (ស្រី: ៥៧.៤៣០, ប្រុស: ១១៣.២២៩) បានចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ តាមរយៈកម្មវិធីចាក់វ៉ាក់សាំងរបស់ក្រសួងសុខាភិបាល។

## ព្រឹត្តិការណ៍ដែលនឹងកើតមាន និងវិធានការអាទិភាព
**ការតាមដានជំងឺ**

- ក្រសួងសុខាភិបាល បានសហការជាមួយនឹងអង្គការសុខភាពពិភពលោកក្នុងការរៀបចំយុទ្ធសាស្ត្រស្វែងរកឲ្យបានឆាប់ ដើម្បីបង្កើនឱកាសស្វែងរកនៅក្នុងសហគមន៍៖ ការពិនិតរករោគសញ្ញារាល់ថ្ងៃនៅតាមមូលដ្ឋានសុខាភិបាលទៅលើរាល់អ្នកជំងឺ និងបុគ្គលិកសុខាភិបាល ព្រមទាំងការធ្វើតេស្តបុគ្គលិកដែលមានចេញរោគសញ្ញាជំងឺស្រដៀងផ្តាសាយ ការធ្វើតេស្តក្រុមពលរដ្ឋដោយឡែកមួយចំនួន



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

(អ្នកបើកឡានធំៗ អ្នករត់ឡានតាក់ស៊ី ប៉ូលីស និងកម្មករប្រមូលសម្រាម) ប្រសិនបើពួកគាត់ចេញរោគសញ្ញាជំងឺស្រដៀងផ្តាសសាយ និងការពិនិត្យករណីមិនបង្ហាញរោគសញ្ញាក្នុងចំណោមបុគ្គលិកពន្ធនាគារ នៅរាជធានីភ្នំពេញរយៈពេល២សប្តាហ៍។

- ជាការឆ្លើយតបនឹងការផ្ទុះជំងឺពាក់ព័ន្ធនឹងព្រឹត្តិការសហគមន៍២០កុម្ភៈនៅខេត្តព្រៃវែង ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក បានធ្វើទស្សនកិច្ចសិក្សាទៅមណ្ឌលសុខភាព នៅតំបន់ពាក់ព័ន្ធ ដើម្បីពិនិត្យមើលឡើងវិញពីទិន្នន័យនៃជំងឺស្រដៀងផ្តាសសាយ និងផ្តល់ការគាំទ្រដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងតាមរកករណី ដោយសម្របសម្រួលការប្រមូលសំណាករបស់អ្នកជំងឺស្រដៀងផ្តាសសាយ។
- មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព និងអង្គការសុខភាពពិភពលោក បាន និងកំពុងអនុវត្តការតាមដាន ជាមួយនឹងការចូលរួមសហគមន៍នៅក្នុងស្រុកមួយនៅខេត្តបាត់ដំបង។ ក្រុមការងារបានផ្តល់វគ្គបណ្តុះបណ្តាលគ្រូបង្គោល១វគ្គដល់ក្រុមការងារនៅស្រុកប្រតិបត្តិ មណ្ឌលសុខភាព និងក្រុមសហគមន៍ ដើម្បីជួយក្នុងការតាមរកករណីវីរុសកូវីដ-១៩នៅក្នុងសហគមន៍។ ដំណើរទស្សនកិច្ចត្រួតពិនិត្យបន្ថែមទៀតនឹងត្រូវធ្វើឡើងជាផ្នែកមួយនៃដំណើរការតាមដាន។
- ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក ក្រសួងសុខាភិបាលនឹងពង្រឹងសមត្ថភាពរាជធានី ខេត្តសម្រាប់ការប្រើប្រាស់មជ្ឈមណ្ឌលប្រតិបត្តិការសង្គ្រោះបន្ទាន់ / ប្រព័ន្ធគ្រប់គ្រងករណីឆ្លងជំងឺ (EOC / IMS) និងការតាមដានប្រភពជាច្រើនសម្រាប់ការវាយតម្លៃហានិភ័យ និងការសម្រេចចិត្ត។

**មន្ទីរពិសោធន៍**

- វិទ្យាស្ថានប៉ាស្ទ័រកម្ពុជាកំពុងធ្វើតេស្ត ការពនិត្យលំដាប់ហ្សែន និងការវិភាគសេរ៉ូហ្ស៊ីនៅមន្ទីរពិសោធន៍។
- ក្រសួងសុខាភិបាល កំពុងតែធ្វើតេស្តមន្ទីរពិសោធន៍ និងការស្រាវជ្រាវរកប្រភពនៃការចម្លង។ ក្រសួងសុខាភិបាល ដោយមានការគាំទ្រពីដៃគូ បាននិងកំពុងតែធ្វើការប្រមូលសំណាក និងតេស្តបន្ថែមទៀត ដើម្បីជួយដល់ការងារតាមដានរកជំងឺពាក់ព័ន្ធនឹងព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ រួមទាំងការគ្រប់គ្រងនិងវិភាគទិន្នន័យមន្ទីរពិសោធន៍។
- ក្រសួងសុខាភិបាល កំពុងសហការជាមួយនឹងអង្គការសុខភាពពិភពលោក វិទ្យាស្ថានសុខភាពសាធារណៈ និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដើម្បីពន្លឿនជម្រើសសម្រាប់បង្កើនសមត្ថភាពធ្វើតេស្ត។
- អង្គការសុខភាពពិភពលោក កំពុងសហការជាមួយនឹងវិទ្យាស្ថានសុខភាពសាធារណៈ និងវិទ្យាស្ថានប៉ាស្ទ័រ ដើម្បីបង្កើនសម្តភាពមន្ទីរពិសោធន៍ថ្នាក់តំបន់សម្រាប់ការវិភាគម៉ូលេគុលវីរុសកូវីដ-១៩ តាមរយៈកម្មវិធីបណ្តុះបណ្តាលសម្តភាពជាបីជំហានដែលនឹងចាប់ផ្តើមពីថ្ងៃច័ន្ទសប្តាហ៍ក្រោយ។
- ក្រសួងសុខាភិបាលកំពុងអនុវត្តដំណើរការ ផែនការពង្រីក និងធ្វើវិមជ្ឈការសមត្ថភាពនៃមន្ទីរពិសោធន៍សម្រាប់ធ្វើតេស្តរកមេរោគជំងឺកូវីដ១៩ ដល់មន្ទីរពិសោធន៍ខេត្តចំនួន៣ គឺខេត្តសៀមរាប ខេត្តព្រះសីហនុ និងខេត្តបាត់ដំបង។ វិទ្យាស្ថានសុខភាពសាធារណៈ បានចាប់ដំណើរការឧបករណ៍ដែលធ្វើតេស្តដោយស្វ័យប្រវត្តិលឿន ដើម្បីពង្រីកសមត្ថភាពតេស្តរបស់មន្ទីរពិសោធន៍។

**អន្តរគមន៍ និងការផ្តល់សេវាសុខភាព**

- ក្រសួងសុខាភិបាលកំពុងត្រួតពិនិត្យអំពីការត្រៀមខ្លួនស្តីពីការគ្រប់គ្រងគ្លីនិកសម្រាប់ការចម្លងសហគមន៍ទ្រង់ទ្រាយធំ។
- នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល កំពុងបញ្ចប់កំណែលើកទី៣.០នៃគោលការណែនាំគ្លីនិក។ គោលការណ៍ណែនាំនេះ មានរួមបញ្ចូលមាតិកាស្តីពីការគ្រប់គ្រងករណីជំងឺធ្ងន់ធ្ងរ ឧបករណ៍ចម្រោះអុកស៊ីសែន និងនីតិវិធីសម្រាប់តាមដានវីរុសកូវីដ-១៩ (SARS-CoV-2) លក្ខណៈវិច្ឆ័យសម្រាប់ការអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យ ការប្រើប្រាស់ឱសថ និងការគ្រប់គ្រងក្រោយពេលចេញពីមន្ទីរពេទ្យ។ សេចក្តីសង្ខេបបច្ចេកទេសមួយស្តីពីជំងឺកូវីដ-១៩ សុខភាពបន្តពូជ មាតា និងទារក ដែលមជ្ឈមណ្ឌលសុខភាពមាតា និងទារកដឹកនាំរៀបចំ នឹងត្រូវធ្វើរួចរាល់ ដើម្បីបំពេញបន្ថែមឲ្យគោលការណ៍ណែនាំគ្លីនិក។

**ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សហគមន៍**

- ក្រសួងសុខាភិបាលកំពុងរៀបចំធ្វើបច្ចុប្បន្នភាពទីតាំង៣ប្រភេទដែលមានមនុស្សច្រើនគួរចៀសវាងជាភាសាចិន វៀតណាម ខ្មែរ និងភាសាអង់គ្លេស ដោយអំពាវនាវឲ្យអ្នកពាក់ព័ន្ធទាំងអស់ទៅធ្វើតេស្ត និងធ្វើចត្តាឡីស័ក។
- សម្ភារៈ និងសារ កំពុងត្រូវបានរៀបចំឡើង និងផ្សព្វផ្សាយៈ



**បដិសេធការទទួលខុសត្រូវៈ** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

  - រាជធានីភ្នំពេញ និងខេត្តកណ្តាល ត្រូវបានអំពាវនាវឲ្យទៅធ្វើតេស្ត ប្រសិនបើមានចេញរោគសញ្ញា
  - អ្នកគ្រប់គ្នាមានហានិភ័យដូចគ្នា ឬបានន័យថាគ្រប់គ្នាត្រូវបង្កើនការប្រុងប្រយ័ត្នទាំងអស់គ្នា
  - ព័ត៌មានក្រាហ្វិករំលឹកពីការធ្វើចត្តាឡីស័កៈ ក្រោយពេលចេញពីមណ្ឌលចត្តាឡីស័ក និងក្រោយពេលតេស្តលើកទី១
- ខិត្តប័ណ្ណស្តីពីប្រការគួរធ្វើ និងមិនគួរធ្វើនៅពេលធ្វើចត្តាឡីស័ក កំពុងត្រូវបានកែសម្រួលឡើងវិញសម្រាប់ជម្រើសពប្រភេទខុសគ្នាៈ នៅផ្ទះ នៅសណ្ឋាគារ ឬនៅមណ្ឌលចត្តាឡីស័ក។
- មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព កំពុងតែកែសម្រួលព័ត៌មានក្នុងកូនសៀវភៅសម្រាប់ក្រុមគាំទ្រសុខភាពភូមិ និងមេភូមិឡើងវិញ ដើម្បីដាក់បញ្ចូលព័ត៌មានទាក់ទិននឹងវ៉ាក់សាំង ហើយនឹងផ្សព្វផ្សាយទូទាំងប្រទេស។
- ក្រសួងសុខាភិបាល ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក អង្គការយូនីសេហ្វ និង GIZ កំពុងអនុវត្តផែនការជម្រុញការការចូលរួមរបស់សហគមន៍ និងការប្រាស្រ័យទាក់ទងអំពីវ៉ាក់សាំង ជាផ្នែកមួយនៃផែនការចែកចាយវ៉ាក់សាំងថ្នាក់ជាតិ។

**អន្តរគមន៍មិនមែនវេជ្ជសាស្ត្រ**

- រដ្ឋាភិបាលកំពុងវាយតម្លៃជាបន្តបន្ទាប់នូវការកែសម្រួលអន្តរាគមន៍មិនមែនវេជ្ជសាស្ត្រ តាមរយៈវិធីសាស្ត្រជាជំហាន បន្តិចម្តងៗ ដោយគិតពីប្រសិទ្ធភាព ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គម និងការទទួលយកបានរបស់ប្រជាពលដ្ឋនូវវិធានការនីមួយៗ ខណៈដែលរដ្ឋាភិបាលកំពុងបង្កើនសមត្ថភាពតាមដានជំងឺដើម្បីប្រមូលព័ត៌មានយកទៅធ្វើសេចក្តីសម្រេចចិត្តឲ្យបានត្រឹមត្រូវ។
- វគ្គចែករំលែកពីរវគ្គអំពីការគាំទ្រសុខភាពផ្លូវចិត្ត និងចិត្តសង្គមនៅក្នុងបរិបទជំងឺកូវីដ-១៩ ត្រូវបានរៀបចំឡើងសម្រាប់បុគ្គលិកមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកស្រុកប្រតិបិត្តចំនួន ៨៩នាក់ កាលពីថ្ងៃទី ៩ដល់ថ្ងៃទី ១២ខែមីនា នៅខេត្តកំពង់ចាម។
- សកម្មភាពចែករំលែកពីរសុខភាពវិជ្ជាជីវៈនៅក្នុងបរិបទជំងឺកូវីដ-១៩ នឹងត្រូវបានរៀបចំឡើងសម្រាប់បុគ្គលិកមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកស្រុកប្រតិបិត្ត និងមន្ទីរពេទ្យបង្អែកនៅភ្នំពេញ ចំនួន ៣៦នាក់ ពីថ្ងៃទី ២៩ដល់ថ្ងៃទី ៣១ខែមីនា ឆ្នាំ២០២១។
- សកម្មភាពបង្កើនការយល់ដឹង និងការតាមដានការងារនៅសហគមន៍ ដើម្បីពង្រឹងការអនុវត្តកម្មវិធីអន្តរាគមន៍មិនមែនវេជ្ជសាស្ត្រ នឹងត្រូវរៀបចំឡើងពីថ្ងៃទី ១៥ ដល់ថ្ងៃទី ១៧ ខែមីនា នៅខេត្តក្រចេះ។ បុគ្គលិកសុខាភិបាលចំនួន ៦០នាក់មកពីមណ្ឌលសុខភាព និងស្រុកប្រិតិបិត្តចំនួន២០ នឹងត្រូវអញ្ជើញឲ្យចូលរួម។

## ការវាយតម្លៃនៃអត្រាឆ្លងជំងឺថ្នាក់ជាតិ

**២. ករណីនាំចូល-** គិតត្រឹមថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១នេះ ករណីវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ៩០០ ករណី (៦៨%) នៃចំនួនករណីសរុប ១.៣២៥ ករណី ត្រូវបានរាយការណ៍ ហើយចំនួនសេសសល់ជាករណីឆ្លងក្នុងប្រទេស។ មិនមានការរាយការណ៍ពីជំងឺផ្លូវដង្ហើមចង្កោមដែលមិនបានធ្វើរោគវិនិច្ឆ័យឃើញ តាមរយៈតាមបណ្តាញទូរស័ព្ទបន្ទាន់នោះទេ។ របាយការណ៍អំពីករណីជំងឺស្រដៀងផ្តាសាយ និងជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរនៅក្នុងខែមីនា មានកម្រិតទាបជាងដែលបានរំពឹងទុក។ មានបុគ្គលចំនួន ៣៣១.០២៧នាក់ បានធ្វើតេស្តរកវីរុសកូវីដ-១៩ ដោយប្រើបច្ចេកវិជ្ជាធ្វើតេស្តបែប PCR (Polymerase chain reaction, PCR) ជាមួយនឹងអត្រាវិជ្ជមានចំនួន ០,៤%។ ការធ្វើតេស្តសរុបមានចំនួន ៤៩៨.៨៤៧ គិតត្រឹមថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២១ ដែលក្នុងនោះមានតេស្តទៅលើសំណាក ៤.៩០១ បានមកពីប្រព័ន្ធតាមដានមានស្រាប់នៃជំងឺស្រដៀងផ្តាសាយ (influenza-like illness, ILI) និងជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (severe acute respiratory infections, SARI)  ទទួលបានលទ្ធផលអវិជ្ជមានវីរុសកូវីដ-១៩ (SARS-CoV-2)។

ការវាយតម្លៃការតាមដានជំងឺដោយប្រើព័ត៌មានពីច្រើនប្រភពសម្រាប់ព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ បញ្ជាក់ថានៅដំណាក់កាលទី១នៃការចម្លង (stage1 transmission) នៅក្នុងខេត្តចំនួន១០។ ទោះជាយ៉ាងណាក៏ដោយ ហានិភ័យនៃការចម្លងជារួមក្រៅពីចង្កោមដែលមានការចម្លង និងការឈានចូលទៅដំណាក់កាលទី២ (កាលចម្លងកម្រិតសហគមន៍) នៅកម្ពុជានៅតែខ្ពស់នៅឡើយ។ បើគិតតាមខេត្តនីមួយៗ ហានិភ័យនៃការឈានទៅចម្លងកម្រិតសហគមន៍ គឺខ្ពស់ខ្លាំងនៅរាជធានីភ្នំពេញ នៅខេត្តព្រះសីហនុ ខេត្តកណ្តាល ហានិភ័យកម្រិតល្មមនៅខេត្តព្រៃវែង និងហានិភ័យកម្រិតទាបនៅខេត្តផ្សេងៗទៀត។ មិនមានភស្តុតាងនៃការឈានដល់ដំណាក់កាលទី២នៃការចម្លងនៅក្នុងខេត្តណាមួយនោះទេ។



**បដិសេធការទទួលខុសត្រូវៈ** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩  ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

World Health Organization
Western Pacific Region

# កម្ពុជា

## របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៣៧

១៥ មីនា ឆ្នាំ២០២១

របាយការណ៍គិតត្រឹមថ្ងៃទី ១៥ មីនា ឆ្នាំ២០២១ ម៉ោង១០:០០នាទីព្រឹក

| បច្ចុប្បន្នភាព អេពីដេមីសាស្ត្រ អំពីកូវីដ-១៩ | ចំនួនតេស្ត | ករណីឈឺ | ករណីស្លាប់ | ករណីសង្គ្រោះបន្ទាន់ |
|---|---|---|---|---|
| | 40.718<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចក្នុងពេល៧ថ្ងៃចុងក្រោយ | 314<br>ករណីវិជ្ជមានថ្មីក្នុងពេល៧ថ្ងៃចុងក្រោយ<br>(64% - ៧ថ្ងៃ) | 1<br>ករណីស្លាប់ក្នុងពេល៧ថ្ងៃចុងក្រោយ<br>(០ភាគរយ-៧ថ្ងៃ) | 2<br>ករណីសង្គ្រោះបន្ទាន់ក្នុងពេល៧ថ្ងៃចុងក្រោយ<br>(១០០ភាគរយ-៧ថ្ងៃ) |
| | 498.847<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចសរុប | 1,325<br>ករណីសរុប | 1<br>ករណីស្លាប់សរុប | 3<br>ករណីសង្គ្រោះបន្ទាន់សរុប |
| | 37<br>ចំនួនករណីនាំចូលពីបរទេសក្នុងពេល២៨ថ្ងៃចុងក្រោយ | 1<br>ចំនួនករណីក្នុងរយៈពេល២៨ចុងក្រោយដែលគ្មានព័ត៌មានពាក់ព័ន្ធ (0) | 19<br>ចង្កោមសកម្ម | 1<br>ចង្កោមសកម្មដោយបានឆ្លងលើសបីតំណ |

| ការផ្តល់សេវាសុខភាព អំពីកូវីដ-១៩ | | | | |
|---|---|---|---|---|
| | 1<br>ចំនួនករណីបុគ្គលិកថែទាំសុខភាពដែលត្រូវបានរាយការណ៍កាលពីសប្តាហ៍កន្លងមក | 27<br>ចំនួនមន្ទីរពេទ្យដែលទទួលអ្នកជំងឺកូវីដ-១៩ ឲ្យសម្រាកព្យាបាល | 13.667<br>ចំនួនគ្រែមន្ទីរពេទ្យរដ្ឋសរុប | 17<br>ចំនួនមន្ទីរពេទ្យដែលមានបទពិសោធន៍គ្រប់គ្រងករណីជំងឺកូវីដ-១៩ |

# អេពីដេមីសាស្ត្រ

**ក្រាហ្វិកទី១. ចំនួនករណីឈឺបញ្ជាក់ដោយមន្ទីរពិសោធន៍បែងចែកតាមស្ថានភាពនៃការឆ្លង និងកាលបរិច្ឆេទនៃលទ្ធផលតេស្តវិជ្ជមាន**

(បានបញ្ចូលករណីដែលមិនស្គាល់ប្រភពចម្លង)






**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**តារាងទី១. តារាងនៃករណីឈឺសរុប និងថ្មី (ក្នុងរយៈពេល៧ថ្ងៃចុងក្រោយ) និងករណីស្លាប់ បែងចែកតាមអាយុ និងភេទ**

| ក្រុមនៃអាយុ | ស្រី | | ប្រុស | | សរុប |
|---|---|---|---|---|---|
| | ករណីឈឺ | ករណីស្លាប់ | ករណីឈឺ | ករណីស្លាប់ | ករណីឈឺ |
| 0-9 | **3(1)** | **0(0)** | **10(3)** | **0(0)** | **13(4)** |
| 10-19 | **36(18)** | **0(0)** | **22(14)** | **0(0)** | **58(32)** |
| 20-29 | **246(45)** | **0(0)** | **279(60)** | **0(0)** | **525(105)** |
| 30-39 | **160(28)** | **0(0)** | **270(59)** | **0(0)** | **430(87)** |
| 40-49 | **50(19)** | **0(0)** | **94(32)** | **0(0)** | **144(51)** |
| 50-59 | **29(8)** | **0(0)** | **41(10)** | **1(1)** | **71(19)** |
| 60-69 | **28(6)** | **0(0)** | **36(3)** | **0(0)** | **64(09)** |
| 70-79 | **6(3)** | **0(0)** | **12(4)** | **0(0)** | **18(07)** |
| 80-89 | **0(0)** | **0(0)** | **0(0)** | **0(0)** | **0(0)** |
| 90+ | **0(0)** | **0(0)** | **0(0)** | **0(0)** | **0(0)** |
| មិនដឹង | **0(0)** | **0(0)** | **2(0)** | **0(0)** | **2(0)** |
| សរុប | **558(128)** | **0(0)** | **766(185)** | **1(1)** | **1,325(314)** |

**ក្រាហ្វិកទី២. ចំនួនសមាមាត្រនៃករណីឈឺបញ្ជាក់ដោយមន្ទីរពិសោធន៍ បែងចែកតាមក្រុមអាយុ និងសញ្ជាតិ (ចំនួន ១.៣២៥នាក់)**






**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**ក្រាហ្វិកទី៣. ចំនួនករណីជំងឺស្រដៀងផ្ដាសាយ (ILI) មកពីកន្លែងតាមដានជំងឺស្រដៀងផ្ដាសាយ (ចំនួន ៧កន្លែង) ប្រចាំសប្ដាហ៍ ឆ្នាំ ២០២១ និងពីឆ្នាំ២០១៨ ដល់ឆ្នាំ ២០២០**




**ក្រាហ្វិកទី៤. ចំនួនករណីជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ ប្រចាំសប្ដាហ៍ ឆ្នាំ២០២១ និងពីឆ្នាំ២០១៨ ដល់២០២០**






**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

# អភិក្រមយុទ្ធសាស្រ្ត

**ការឆ្លើយតបសុខភាពសាធារណៈនៅថ្នាក់ជាតិ និងរាជធានី-ខេត្ត**

## ប្រព័ន្ធគ្រប់គ្រងឧប្បត្តិហេតុ

- គណៈកម្មាធិការអន្តរក្រសួង ដែលដឹកនាំដោយរដ្ឋមន្រ្តីក្រសួងសុខាភិបាល និងជាមួយនឹងរដ្ឋលេខាធិការ
- គណៈកម្មាធិការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩ ដែលដឹកនាំដោយសម្តេចតេជោនាយករដ្ឋមន្រ្តី
- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺកូវីដ១៩ថ្នាក់រាជនានី-ខេត្ត ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
- គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានក្រុមការងារបច្ចេកទេស៤ក្រុមសម្រាប់ដោះស្រាយផលប៉ះបាល់ផ្នែកសេដ្ឋកិច្ច និងសង្គមបង្កឡើងដោយជំងឺកូវីដ-១៩

## ការអភិវឌ្ឍប្រព័ន្ធ និងគោលនយោបាយ

- ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រិត្យនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ មិនទាន់ត្រូវបានអនុវត្តនៅឡើយទេ។
- ទំរង់ Go.Data (Go.Data Platform) ត្រូវបានប្រើជាមូលដ្ឋានទិន្នន័យមួយសម្រាប់ប្រមូលព័ត៌មានអំពីអ្នកប៉ះពាល់ជាមួយករណីកូវីដ-១៩វិជ្ជមាន និងព័ត៌មានមន្ទីរពិសោធន៍។
- មូលដ្ឋានទិន្នន័យរបស់វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ត្រូវបានកែសម្រួលដើម្បីអាចបញ្ចូលសំណុំទិន្នន័យប្រភពច្រើនសម្រាប់ការធ្វើតេស្ត និងតាមដានជំងឺ។

## គន្លឹះអាទិភាពសំខាន់ៗ

- នាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងសុខាភិបាល កំពុងរៀបចំបង្កើតយុទ្ធសាស្ត្រថែទាំសុខភាពបឋមសម្រាប់ជំងឺកូវីដ-១៩។ ឯកសារនេះ នឹងដាក់បញ្ចូលតួនាទី និងភារកិច្ចនានារបស់មណ្ឌលសុខភាពនៅក្នុងសេណារីយ៉ូមួយដែលអាចកើតមាននូវការឆ្លងជំងឺកូវីដ-១៩ទៅក្នុងសហគមន៍ ក៏ដូចជាគោលការណ៍គ្រប់គ្រងគ្លីនិក និងការបង្ការ និងត្រួតពិនិត្យការឆ្លងរោគ។
- នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល កំពុងធ្វើការស្ទង់មតិមួយអំពីវគ្គបណ្តុះបណ្តាលកន្លងមកពីការគ្រប់គ្រងគ្លីនិក ការបង្ការនិងត្រួតពិនិត្យការឆ្លងរោគ ដើម្បីរៀបចំបង្កើតកម្មវិធីសិក្សាថ្នាក់ជាតិមួយសំរាប់បញ្ហាជំងឺកូវីដ-១៩។
- នាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល កំពុងធ្វើការវាយតម្លៃទាក់ទងនឹងការត្រៀមខ្លួនរបស់ប្រព័ន្ធសុខាភិបាល នៅតាមមូលដ្ឋានថែទាំសុខភាព ទាក់ទងនឹងសមត្ថភាពសង្គ្រោះបន្ទាន់ (ICU) អុកស៊ីសែន បុគ្គលិកសុខាភិបាលជាដើម។
- កម្មវិធីថ្នាក់ជាតិកំពុងតែអភិវឌ្ឍផែនការឆ្លើយតប និងត្រៀមបង្ការដោយផ្តោតជាសំខាន់ទៅលើជំងឺកូវីដ-១៩។
- កំពុងដាក់ឲ្យអនុវត្តយុទ្ធសាស្ត្រពង្រីកមន្ទីរពិសោធន៍ និងផែនការធ្វើរោគវិនិច្ឆ័យម៉ូលេគុលដើម្បីធានាឲ្យមានការធ្វើតេស្តគ្រប់គ្រាន់ជាប្រចាំសម្រាប់ជំងឺកូវីដ-១៩នៅថ្នាក់ជាតិ និងថ្នាក់តំបន់។
- ការពង្រឹងការធ្វើចត្តាឡីស័កនៅតាមមូលដ្ឋានថែទាំសុខភាព ដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងវីរុសកូវីដ-១៩ ដោយបង្កើតជាឧបករណ៍ជំនួយការងារសាមញ្ញៗសម្រាប់បុគ្គលិកនៅមូលដ្ឋានថែទាំសុខភាព។
- គោលការណែនាំស្តីពីការតាមដានជំងឺ ការស្វែងរកអ្នកពាក់ព័ន្ធនឹងអ្នកមានជំងឺកូវីដ-១៩ របស់ក្រសួងសុខាភិបាល ត្រូវបានធ្វើបច្ចុប្បន្នភាព ដោយដាក់បញ្ចូលនិយមន័យករណីសង្ស័យជំងឺកូវីដ-១៩ថ្មីដែលដាក់បញ្ចូលតំបន់មានការចម្លងក្នុងសហគមន៍ (បច្ចុប្បន្នភាពនៅថ្ងៃទី០៧ មករា ឆ្នាំ២០២១)។
- ការបង្កើតផែនការអនុវត្តន៍សម្រាប់ការប្រើប្រាស់ការតាមដានជំងឺដោយប្រើពហុប្រភពព័ត៌មាននៅកម្រិតថ្នាក់ក្រោមជាតិសម្រាប់វាយតម្លៃហានិភ័យ និងការធ្វើសេចក្តីសម្រេចចិត្ត។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្ន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- ពង្រឹងសមត្ថភាពត្រៀមបង្ការនៅថ្នាក់មូលដ្ឋាន ក្នុងករណីមានការផ្ទុះរាលដាលជំងឺនៅសហគមន៍នាពេលអនាគត និងដើម្បីកាត់បន្ថយការរាំងស្ទះដល់ដំណើរការផ្តល់សេវាសុខភាពសំខាន់ៗ។

### អភិក្រមយុទ្ធសាស្ត្រសម្រាប់បង្ការ ស្រាវជ្រាវ និងត្រួតពិនិត្យជំងឺកូវីដ-១៩

- *យុទ្ធសាស្ត្រសម្រាប់ការធ្វើតេស្ត និងប្រព័ន្ធស្វែងរកអ្នកប៉ះពាល់មានរួចរាល់*

យុទ្ធសាស្ត្រធ្វើតេស្តទូលំទូលាយមួយ កំពុងត្រូវបានអនុវត្តនៅទូទាំងប្រទេស ដែលរួមមានការធ្វើតេស្តករណីសង្ស័យទាំងអស់ដែលចូលក្នុងនិយមន័យករណីសង្ស័យមានជំងឺកូវីដ-១៩ និងការឃ្លាំមើលយ៉ាងសកម្មចំពោះករណីជំងឺរលាកសាច់សួត (pneumonia) នៅតាមមន្ទីរពេទ្យ ក៏ដូចជាការធ្វើតេស្តនៅច្រកចេញ-ចូល (points of entry) នាថ្ងៃទី១ និងថ្ងៃទី១៣ ពេលបញ្ចប់ចត្តាឡីស័ក១៤ ថ្ងៃ និងការធ្វើតេស្តវត្ថុវិភាគបានមកពីប្រព័ន្ធតាមដានមានស្រាប់នៃជំងឺស្រដៀងផ្តាសាយ (ILI) និងជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARI) ដើម្បីកំណត់រកមេរោគកូវីដ-១៩។ យុទ្ធសាស្ត្រតាមដានជំងឺ កំពុងត្រូវបានអនុវត្តនៅពេលចាំបាច់ នៅតាមតំបន់ដែលប្រឈមខ្ពស់ ឬតំបន់ដែលមានករណីវីរុសកូវីដ-១៩ ច្រើន (Hot-spot surveillance strategies) ក៏ដូចការធ្វើតេស្តទៅលើក្រុមប្រជាជនដែលមានហានិភ័យខ្ពស់ (high-risk populations)។

- *ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សគមន៍*

យុទ្ធសាស្ត្រសម្រាប់ស្រាវជ្រាវរកជំងឺដោយមានការចូលរួមរបស់សហគមន៍ ត្រូវបានបង្កើតឡើង និងដាក់សាកល្បងដើម្បីស្វែករកករណីជំងឺកូវីដ-១៩ នៅកម្រិតមណ្ឌលសុខភាប និងសហគមន៍។ ក្រសួងមហាផ្ទៃ កំពុងជម្រុញការត្រួតពិនិត្យនៅតាមមណ្ឌលចត្តាឡីស័កតាមរយៈការតាមដាន និងពិន័យសម្រាប់បុគ្គលដែលបំពានគោលការណ៍ណែនាំ។ យុទ្ធសាស្ត្រជម្រុញការចូលរួមរបស់សហគមន៍កំពុងត្រូវបានបង្កើតឡើង ហើយក្រសួងសុខាភិបាលបានបង្កើតផែនការគ្រប់គ្រង និងតាមដានការចូលរួម និងការប្រាស្រ័យទាក់ទងជាសហគមន៍ ដែលត្រូវអនុវត្តពីខែឧសភា ដល់ខែកក្កដាឆ្នាំ២០២០ សម្រាប់បុគ្គលិកសុខាភិបាល និងបុគ្គលិកភូមិនៅក្នុងខេត្តចំនួន១២។

- *អន្តរាគមន៍សុខភាពសាធារណៈមិនមែនវេជ្ជសាស្ត្រ (មាននៅក្នុងតារាងនៅចុងបញ្ចប់នៃរបាយការណ៍នេះ)*

## បទពិសោធន៍ល្អៗ និងមេរៀនដែលទទួលបាន

### កត្តាដែលបានរួមចំណែកដល់ការឆ្លើយតបបានល្អ

- **ភាពជាអ្នកដឹកនាំខ្លាំង និងការសម្របសម្រួលបានល្អ**
  - ការឆ្លើយតបរបស់រដ្ឋាភិបាល និងសង្គមទាំងមូល ដឹកនាំដោយសម្តេចតេជោនាយករដ្ឋមន្ត្រី ហើយវិធានការសុខភាពសាធារណៈដឹកនាំដោយរដ្ឋមន្ត្រីសុខាភិបាល។
  - ផែនការមេថ្នាក់ជាតិសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវបានរៀបចំឡើងជាមួយនឹងថវិកាចំនួន ៦២លានដុល្លារសហរដ្ឋអាមេរិកសម្រាប់ឆ្នាំទី១។
- **ការវិនិយោគកន្លងមកបានពង្រឹងដំណើរការប្រព័ន្ធសុខភាពសុខភាពសាធារណៈ**
  - ការតាមដានជំងឺកូវីដ-១៩ ដោយបានពីព័ត៌មានពហុប្រភព រួមទាំងប្រព័ន្ធឃ្លាំមើលជំងឺកូវីដ-១៩ ដោយប្រើប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ (១១៥) និងប្រព័ន្ធតាមដានមានស្រាប់នៃជំងឺស្រដៀងផ្តាសាយ (ILI) និងជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARI)។
  - ក្រុមឆ្លើយតបបន្ទាន់ជិត ៣.០០០នាក់ នៅទូទាំងប្រទេស បានស្រាវជ្រាវរកករណី និងតាមរកអ្នកប៉ះពាល់ជាមួយនឹងករណីវិជ្ជមានវីរុសកូវីដ-១៩។
- **ការទំនាក់ទំនង និងផ្សព្វផ្សាយហានិភ័យ និងការចូលរួមរបស់សហគមន៍**



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- សារទាន់ពេលវេលា ត្រូវបានផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ និងបណ្ដាញសង្គម និងតាមរយៈសេចក្ដីជូនព័ត៌មានទៀងទាត់ និងសន្និសីទសារព័ត៌មាន។
- សម្ភារទំនាក់ទំនងសម្រាប់ទស្សនិកជន និងអ្នកស្ដាប់គោលដៅ ត្រូវបានបង្កើតឡើងសម្រាប់ក្រុមដែលមានហានិភ័យខ្ពស់ ដូចជាជនទេសន្តប្រវេសន៍(ពលករចំណាកស្រុក) និងកម្មកររោងចក្រ។
- យុទ្ធសាស្ត្រជម្រុញការចូលរួមរបស់សហគមន៍ ត្រូវបានអនុវត្តដើម្បីគ្របដណ្ដប់គ្រប់ផ្នែកនៃការតាមដានជំងឺ និងការឆ្លើយតបចំពោះជំងឺកូវីដ-១៩ ជាពិសេសត្រៀមសម្រាប់ពេលមានការឆ្លងទៅសហគមន៍ណាមួយ។

- **សាមគ្គីភាព និងសហប្រតិបត្តិការអន្តរជាតិ**
  - ការឆ្លើយតបដោយប្រព័ន្ធសុខាភិបាលមួយដែលមានតម្លាភាព និងបើកចំហ។
  - កិច្ចសហការបច្ចេកទេស និងប្រតិបិត្តិការជិតស្និទ្ធរវាងទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ដទៃទៀត។
  - ការចូលរួមនៃមន្ត្រីជាន់ខ្ពស់នៅកិច្ចប្រជុំអន្តរជាតិនានា រួមទាំងការសម្របសម្រួលជាទៀងទាត់ក្នុងចំណោមបុគ្គលិកទទួលបន្ទុកផ្នែកច្បាប់និយ័តកម្មអន្តរជាតិឆ្នាំ២០០៥ របស់អង្គការសុខភាពពិភពលោក។

## ការចាក់វ៉ាក់សាំងកូវីដ-១៩

- ភាពកម្មវិធីចាក់វ៉ាក់សាំង COVISHIELD (AZ/SII) ត្រូវផ្អាកដោយសារមានអ្នកស្ម័គ្រចិត្តប្រជ្រៀតគ្នាខ្លាំងពេកនៅតាមមណ្ឌលចាក់វ៉ាក់សាំងនៅភ្នំពេញ។ ការចាក់វ៉ាក់សាំងត្រូវបានធ្វើបន្តចាប់ពីថ្ងៃទី ១០មីនា។
- សេវាចុះឈ្មោះចាក់វ៉ាក់សាំងតាមអនឡាញត្រូវបានបង្កើតឡើង ប៉ុន្តែបច្ចុប្បន្នមានតែការចុះឈ្មោះនៅតាមមណ្ឌលផ្ទាល់ទេដែលដំណើរការ។
- សេវាចាក់វ៉ាក់សាំងស៊ីណូហ្វាម ត្រូវបានផ្ដល់ជូននៅតាមមន្ទីរពេទ្យរដ្ឋទាំងអស់នៅទូទាំងរាជធានី-ខេត្ត និងស្រុកប្រតិបត្តិ។
- ក្រសួងសុខាភិបាល បានប្រកាសកាលពីថ្ងៃទី ៥ ខែមិនា ឆ្នាំ២០២១ដោយបញ្ជាក់ថាវ៉ាក់សាំងអាស្ត្រាហ្សេណេកា (Covishield) នឹងត្រូវចាក់ជូនទៅក្រុមអាទិភាព ជាពិសេសអ្នកមានអាយុចាប់ពី ៦០ឆ្នាំឡើងទៅ ដែលរស់នៅរាជធានីភ្នំពេញ ខេត្តកណ្ដាល និងខេត្តព្រះសីហនុ។
- គិតត្រឹមថ្ងៃទី ១០ ខែមីនា ឆ្នាំ២០២១ មិនទាន់មានការរាយការណ៍ណាមួយពីផលរំខានដោយសារការចាក់វ៉ាក់សាំងនោះទេ។

## អន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ (Non-Pharmaceutical Interventions, NPIs)

**ព្រឹត្តិការណ៍សហគមន៍ថ្ងៃទី២០កុម្ភៈ**

- គិតត្រឹមថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០២១ អាជ្ញាធរខេត្តចំនួន៥ គឺខេត្តស្វាយរៀង ប៉ៃលិន ព្រះវិហារ កំពត និងខេត្តឧត្តរមានជ័យ បានប្រកាសពីការផ្អាកការរៀបចំពិធីអាពាហ៍ពិពាហ៍ ពិធីជប់លៀង និងការជួបជុំបែបសាសនាផ្សេងៗ។
- នៅថ្ងៃទី ១០ មីនា ក្រសួងអប់រំ យុវជន និងកីឡា បានប្រកាសផ្អាកសាលារៀនទាំងអស់ ទាំងរដ្ឋ និងឯកជននៅក្នុងខេត្តព្រៃវែង ចាប់ពីថ្ងៃទី ១០ មីនាតទៅរហូតដល់មានការជូនដំណឹងជាថ្មី។
- កាលពីថ្ងៃទី ៩ ខែមិនា សម្ដេចអគ្គមហាសេនាបតីតេជោហ៊ុនសែន បានផ្ញើសារជាសម្លេងស្នើរឲ្យក្រុមហ៊ុនឯកជនទាំងអស់ បើអាចត្រូវកាត់បន្ថយចំនួនបុគ្គលិកធ្វើការនៅការិយាល័យ ហើយរៀបចំការធ្វើការបែបផ្សេងៗជំនួសវិញដូចជាឆ្លាស់វេនគ្នាទៅធ្វើការជាដើម។
- កាលពីថ្ងៃទី ៩ ខែមីនា រដ្ឋបាលខេត្តកណ្ដាល បានប្រកាសពីការរឹតបន្តឹងការធ្វើដំណើរទៅកាន់ទីប្រជុំជនជ្រៃធំ ខេត្តកណ្ដាល។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- កាលពីថ្ងៃទី ២១កុម្ភៈ ឆ្នាំ២០២១ ក្រសួងសុខាភិបាលបានប្រកាសអំពីការដាក់ប្រើប្រព័ន្ធ QR កូដ "បញ្ឈប់កូវីដ-១៩" បង្កើតដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។
- នៅថ្ងៃទី ២០ ខែកុម្ភៈ សេចក្តីប្រកាសព័ត៌មានដោយនាយករដ្ឋមន្ត្រី ជូនដំណឹងអំពី៖
    - ការបិទក្លឹបកំសាន្ត និងទីតាំងផ្សេងៗទៀតនៅជិតតំបន់ដែលមានឆ្លងករណីកូវីដ-១៩
    - លើកទឹកចិត្តឲ្យបុគ្គលដែលពាក់ព័ន្ធនឹងករណីវិជ្ជមានវីរុសកូវីដ-១៩ ករណីឲ្យទៅធ្វើតេស្ត
    - រម្លឹកសាធារណជនអំពីការអនុវត្តបីការពារ និងបីកុំ និងលើកទឹកចិត្តកុំឲ្យមានការរើសអើងចំពោះជនជាតិចិន
    - ដោយត្រូវធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ ពលករចំណាកស្រុកជនជាតិខ្មែរ ត្រូវបានអំពាវនាវកុំឲ្យត្រលប់ពីប្រទេសថៃមកកម្ពុជាវិញ ដើម្បីចូលរួមអបអរពិធីបុណ្យចូលឆ្នាំខ្មែរនៅខែមេសាខាងមុខ
- កាលពីថ្ងៃទី ២០ ខែកុម្ភៈឆ្នាំ២០២១ ក្រសួងអប់រំ យុវជននិងកីឡា បានចេញសេចក្តីប្រកាសមួយស្តីអំពីការរឹតត្បិតលើការអនុវត្តវិធានការសុវត្ថិភាព និងសុខភាព នៅតាមគ្រឹះស្ថានអប់រំសាធារណៈ និងឯកជន នៅទីក្រុងភ្នំពេញ៖
    - ផ្អាកជាបណ្តោះអាសន្ន នូវការជួបជុំ និងសកម្មភាពកីឡាទាំងឡាយណាដែលមានគ្នាលើសពី២០នាក់
    - បុគ្គលិក ត្រូវបានចាត់តាំងជាអ្នកតំណាងសម្រាប់ទំនាក់ទំនងសម្រាប់ការតាមដានការអនុវត្តវិធានធ្វើចត្តាឡីស័ក



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**តារាងទី២ . ការអនុវត្តអន្តរាគមន៍សុខភាពសាធារណៈមិនមែនឱសថ និងថ្ងៃដែលលើកបម្រាមវិញ (NPI implementation and lifting dates)**

| អន្តរាគមន៍សុខភាពសាធារណៈ មិនមែនវេជ្ជសាស្ត្រ( NPI) | ស្ថានភាពត្រួតពិនិត្យ (Monitoring status) | | | | | |
|---|---|---|---|---|---|---|
| | | | ការអនុវត្ត (Implementation) | | ការលើកបម្រាមវិញដោយផ្នែក (Partial lift) | លើកបម្រាមវិញ (Lifted) |
| | ថ្ងៃទី១នៃការអនុវត្ត (Date first implemented) | ថ្ងៃកែប្រែចុងក្រោយ (Date last modified) | ភូមិសាស្ត្រ (ថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ) Geographical (national or sub-national) | ណែនាំឲ្យ ឬ តម្រូវឲ្យ (Recommended or Required) | លើកសម្រាប់ វិស័យ/ផ្នែកខ្លះ (Lifted for some area) | លើកសម្រាប់វិស័យ/ផ្នែកទាំងអស់ (Lifted for all areas) |
| ពាក់ម៉ាស់ការពារ អនាម័យដៃ និងផ្លូវដង្ហើម | មិនមានទេ (None) | មិនមានទេ (None) | | | | |
| បិទសាលារៀន (School Closure) | ១៦ មិនា | ១០ មីនា ឆ្នាំ២០២១ | ថ្នាក់ក្រោមជាតិ | តម្រូវឲ្យ (Required) | បានលើកហើយ (Yes) | មិនទាន់លើកទេ (No) |
| បិទកន្លែងធ្វើការ (Workplace Closure) | មិនមានទេ (None) | មិនមានទេ (None) | | | | |
| ការជួបជុំមនុស្សម្នាច្រើន (Mass Gatherings) | ៣ មេសា | ២៩ ធ្នូ | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | មិនទាន់លើកទេ (No) | មិនទាន់លើកទេ (No) |
| នៅផ្ទះ (Stay at Home) | រដ្ឋាភិបាលស្នើឲ្យនៅផ្ទះប្រសិនបើអាចធ្វើបាន (Government recommends stay home if possible) | មិនមានទេ (None) | | | | |
| រឹតបន្តឹងការធ្វើដំណើរនៅក្នុងប្រទេស (Restrictions on Internal Movement (within country)) | ៩ មេសា | ០៩ មីនា ឆ្នាំ២០២១ | ថ្នាក់ក្រោមជាតិ | ណែនាំឲ្យ (Recommended) | ទេ (No) | លើកទាំងស្រុង (Yes) |
| ការរឹតបន្តឹងលើការធ្វើដំណើរអន្តរជាតិ (Restrictions on International Travel) | ២៧ មិនា | ១១ វិច្ឆិកា | ថ្នាក់ជាតិ | តម្រូវឲ្យ (Required) | បានលើកហើយ (Yes) | មិនទាន់ទេ (No) |
| ផ្សេងៗទៀត សូមបញ្ជាក់ដោយពណ៌នា (Others; specify in narrative) | មិនមានទេ (None) | មិនមានទេ (None) | - | - | - | - |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។